00637088


ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres extraordinaires au sein des tribunaux cambodgiens

អង្គបុរេជំនុំជម្រះ
Pre-Trial Chamber
Chambre Préliminaire


D427/3/13

**តាងនាមប្រជារាស្ត្រខ្មែរ និងតាងនាមអង្គការសហប្រជាជាតិ និងអនុលោមតាមច្បាប់ ស្តីពីការបង្កើតឲ្យមានអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដើម្បីកាត់សេចក្តីឧក្រិដ្ឋកម្ម ដែលបានប្រព្រឹត្តឡើងក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ**

**សំណុំរឿងព្រហ្មទណ្ឌលេខ: ០០២/១៩-០៩-២០០៧-អវតក/កសចស** (អបជ១៤៥ និងអបជ១៤៦)

**ចំពោះមុខ:**
ចៅក្រម ប្រាក់ គឹមសាន ប្រធាន
ចៅក្រម Rowan DOWNING
ចៅក្រម ន៉ីយ ថុល
ចៅក្រម Catherine MARCHI-UHEL
ចៅក្រម ហួត វុទ្ធី

**កាលបរិច្ឆេទ:** ថ្ងៃទី២១ ខែមករា ឆ្នាំ២០១១

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/Date de reception): 21 / 01 / 2011
ម៉ោង (Time/Heure): 15:10
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: Uch Arun

---

**សាធារណៈ**

**សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ អៀង ធីរិទ្ធ និង នួន ជា ប្រឆាំងនឹងដីកាដំណោះស្រាយ៖ សំអាងហេតុសម្រាប់ការបន្តឃុំខ្លួនបណ្តោះអាសន្ន**

---

**សហព្រះរាជអាជ្ញា**
ជា លាង
Andrew CAYLEY

**មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី**
ឡោ ជុនធី

**ជនជាប់ចោទ**
អៀង ធីរិទ្ធ
នួន ជា

**សហមេធាវីការពារក្តីជនជាប់ចោទ**
ផាត់ ពៅស៊ាង
Diana ELLIS

00637089

០០២/១៩-០៩-២០០៧-អវតក/កសចស (អបជ១៤៥ និង១៤៦)

លេខ/No: D427/3/13

ឡោ ជុនធី
គង់ ពិសី
ហុង គីមសួន
យុង ផានិត
គីម ម៉េងឃី
ម៉ុច សុវណ្ណារី
Martine JACQUIN
Philippe CANONNE
Elizabeth RABESANRATANA
Mahdev MOHAN
Olivier BAHOUGNE
Silke STUDZINSKY
DELAHAIE Annie
Fabienne TRUSSES-NAPROUS
ស៊ិន សុវ៉ន
BEAUDOIN Patrick
GUIRAUD Marie
LYMA NGUYEN
វ៉ែន ពៅ
ជេត វណ្ណលី
DESFORGES Laure
DURAND Isabelle
GAUTRY Francoise
MARTINEAU Christine
Pascal AUBOIN
Ferdinand DJAMMEN- Nzepa
Emmanuel ALTIT
Emmanuel JACOMY
Julien RIVET
Barnabe NEKUIE
Nicole DUMAS
Daniel LOSQ
ពេជ អង្គ

Diana ELLIS
សុន អរុណ
Michiel PESTMAN
Victor KOPPE

<u>**សហចៅក្រមស៊ើបអង្កេត**</u>

យូ ប៊ុនឡេង
Siegfried BLUNK

**អង្គបុរេជំនុំជម្រះ** នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ("អ.វ.ត.ក") បានទទួលបណ្តឹងឧទ្ធរណ៍របស់ក្រុមមេធាវីការពារក្តី អៀង ធីរិទ្ធ ប្រឆាំងនឹងដីកាដំណោះស្រាយ ("បណ្តឹងឧទ្ធរណ៍របស់ អៀង ធីរិទ្ធ")[១] ដែលបានដាក់កាលពីថ្ងៃទី១៨ ខែតុលា ឆ្នាំ២០១០ និងបណ្តឹងឧទ្ធរណ៍របស់ នួន ជា ប្រឆាំងនឹងដីកាដំណោះស្រាយ ("បណ្តឹងឧទ្ធរណ៍របស់ នួន ជា")[២] ដែលបានដាក់នៅថ្ងៃទី១៨ ខែតុលា ឆ្នាំ២០១០ បន្ទាប់គ្នា។

១. នៅថ្ងៃទី១៣ ខែមករា ឆ្នាំ២០១១ អង្គបុរេជំនុំជម្រះបានប្រកាសជាស្ពាពរលើបណ្តឹងឧទ្ធរណ៍ និងបានផ្សាយថា សំអាងហេតុសម្រាប់គាំទ្រសាលដីកានេះ នឹងធ្វើទៅតាមពេលវេលាសមស្រប។

២. ជាពិសេស អង្គបុរេជំនុំជម្រះសម្រេចជាឯកច្ឆន្ទថា៖

១. បណ្តឹងឧទ្ធរណ៍អាចទទួលយកបានតាមទម្រង់។

២. មូលដ្ឋានទីមួយ ទីពីរ ទីបី ទីបួន និងទីប្រាំ នៃបណ្តឹងឧទ្ធរណ៍របស់ នួន ជា និង មូលដ្ឋានទីមួយ ទីពីរ ទីបី ទីបួន ទីប្រាំ (ផ្នែកខ្លះ) និងទីប្រាំពីរ (ផ្នែកខ្លះ) នៃបណ្តឹងឧទ្ធរណ៍របស់ អៀង ធីរិទ្ធ អាចទទួលយកបាន។ មូលដ្ឋានដែលនៅសេសសល់ដទៃទៀតនៃបណ្តឹងឧទ្ធរណ៍ មិនអាចទទួលយកបានទេ។ ភាពមិនអាចទទួលយកបាននៃអនុមូលដ្ឋានទីប្រាំ និងទីប្រាំពីរ នៃបណ្តឹងឧទ្ធរណ៍របស់ អៀង ធីរិទ្ធ មានដូចជា៖

- មូលដ្ឋានទីប្រាំ ដែលបានលើកឡើងថា សេចក្តីសម្រេចរបស់សហចៅក្រមស៊ើបអង្កេតក្នុងការបញ្ជាក់អះអាងអំពីយុត្តាធិការ ពាក់ព័ន្ធនឹងឧក្រិដ្ឋកម្មជាតិដែលត្រូវ

---

[១] បណ្តឹងឧទ្ធរណ៍របស់ក្រុមមេធាវីការពារក្តី អៀង ធីរិទ្ធ ប្រឆាំងនឹងដីកាដំណោះស្រាយ ចុះថ្ងៃទី១៨ ខែតុលា ឆ្នាំ២០១០ ឯកសារ D427/2/1 ("បណ្តឹងឧទ្ធរណ៍របស់ អៀង ធីរិទ្ធ")។

[២] បណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ ចុះថ្ងៃទី១៨ ខែតុលា ឆ្នាំ២០១០ ឯកសារ D427/3/1 ("បណ្តឹងឧទ្ធរណ៍របស់ នួន ជា")។



PRE-TRIAL CHAMBER E.C.C.C. C.E.T.C. CHAMBRE PRÉLIMINAIRE

បានចោទប្រកាន់តាមក្រមព្រហ្មទណ្ឌឆ្នាំ១៩៥៦ ជាការរំលោភលើសិទ្ធិស្មើភាពគ្នាចំពោះមុខច្បាប់របស់ អៀង ធីរិទ្ធ។

- មូលដ្ឋានទីប្រាំពីរ ដែលបានលើកឡើងថា សហចៅក្រមស៊ើបអង្កេតខកខានមិនបានធ្វើការជជែកវែកញែកឱ្យបានត្រឹមត្រូវថាជាបញ្ហាអង្គហេតុអត្ថិភាពនៃកាតព្វកិច្ចផ្លូវច្បាប់ដែលត្រូវបំពេញ និងមូលដ្ឋាននៅក្នុងច្បាប់ជាតិជាធាតុផ្សំមួយនៃការទទួលខុសត្រូវរបស់ថ្នាក់លើ។

៣. មូលដ្ឋានទីមួយនៃបណ្តឹងឧទ្ធរណ៍របស់ នួន ជា ត្រូវបានបដិសេធ។

៤. មូលដ្ឋានទីពីរនៃបណ្តឹងឧទ្ធរណ៍របស់ នួន ជា ត្រូវបានបដិសេធ។

៥. មូលដ្ឋានទីបីនៃបណ្តឹងឧទ្ធរណ៍របស់ នួន ជា ត្រូវបានបដិសេធ។

៦. មូលដ្ឋានទីបួននៃបណ្តឹងឧទ្ធរណ៍របស់ នួន ជា ត្រូវបានបដិសេធ។

៧. មូលដ្ឋានទីប្រាំនៃបណ្តឹងឧទ្ធរណ៍របស់ នួន ជា ត្រូវបានបដិសេធ។

៨. មូលដ្ឋានទីមួយនៃបណ្តឹងឧទ្ធរណ៍របស់ អៀង ធីរិទ្ធ ត្រូវបានបដិសេធ។

៩. មូលដ្ឋានទីពីរនៃបណ្តឹងឧទ្ធរណ៍របស់ អៀង ធីរិទ្ធ ត្រូវបានបដិសេធ។

១០. មូលដ្ឋានទីបីនៃបណ្តឹងឧទ្ធរណ៍របស់ អៀង ធីរិទ្ធ ត្រូវបានបដិសេធ។

១១. មូលដ្ឋានទីបួននៃបណ្តឹងឧទ្ធរណ៍របស់ អៀង ធីរិទ្ធ ត្រូវបានអនុញ្ញាតផ្នែកខ្លះដូចខាងក្រោម រីឯផ្នែកផ្សេងទៀតត្រូវបានបដិសេធ។

១- មូលដ្ឋាននៃបណ្តឹងឧទ្ធរណ៍នេះ ត្រូវបានអនុញ្ញាតដរាបណាសហមេធាវីការពារក្តីអះអាងថា សហចៅក្រមស៊ើបអង្កេតមានកំហុសឆ្គងដោយខកខានមិនបានធ្វើការពិចារណាថា នៅក្នុងអំឡុងពេលយុត្តាធិការតាមពេលវេលារបស់ អ.វ.ត.ក ច្បាប់ទំនៀមទម្លាប់អន្តរជាតិ បានតម្រូវឱ្យមានចំណងពាក់ព័ន្ធគ្នារវាងអំពើជាមូលដ្ឋាននៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ និងជម្លោះប្រដាប់អាវុធអន្តរជាតិ។ "អត្ថិភាពនៃចំណងពាក់ព័ន្ធរវាងអំពើជាមូលដ្ឋាន និងជម្លោះប្រដាប់អាវុធអន្តរជាតិ" ត្រូវ

00637092



បានបូកបន្ថែមជាលក្ខខណ្ឌតម្រូវ "ធាតុផ្សំ" មួយនៅក្នុងផ្នែកទី IV(ក) ជំពូកបី នៃដីកាដំណោះស្រាយ។

២- មូលដ្ឋាននៃបណ្តឹងឧទ្ធរណ៍នេះ ត្រូវបានអនុញ្ញាតដរាបណាសហមេធាវីការពារក្តីអះអាងថា ការរំលោភផ្លូវភេទមិនមែនជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនោះទេក្នុងរយៈពេលពីឆ្នាំ១៩៧៥ ដល់ឆ្នាំ១៩៧៩។ ហេតុដូច្នេះ អង្គបុរេជំនុំជម្រះសម្រេចដកការរំលោភផ្លូវភេទចេញពីកថាខណ្ឌ ១៦១៣ (ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ កថាខណ្ឌ (ឆ)) នៃដីកាដំណោះស្រាយ និងរក្សាទុកការយល់ឃើញរបស់សហចៅក្រមស៊ើបអង្កេត នៅក្នុងកថាខណ្ឌ ១៤៣៣ នៃដីកាដំណោះស្រាយថា "អង្គហេតុដែលត្រូវបានកំណត់ថាជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ក្រោមទម្រង់ជាការរំលោភផ្លូវភេទ អាចត្រូវបានកំណត់ជាលក្ខណៈបន្ទាប់បន្សំថាជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិដែលបង្កឡើងពីអំពើអមនុស្សធម៌ដទៃទៀត"។

១២. ផ្នែកទាំងឡាយនៃមូលដ្ឋានទីប្រាំនៃបណ្តឹងឧទ្ធរណ៍របស់ អៀង ធីរិទ្ធ ដែលត្រូវបានយល់ឃើញថាអាចទទួលយកបាន ត្រូវបានបដិសេធ។

១៣. ផ្នែកទាំងឡាយនៃមូលដ្ឋានទីប្រាំពីរនៃបណ្តឹងឧទ្ធរណ៍របស់ អៀង ធីរិទ្ធ ដែលត្រូវបានយល់ឃើញថាអាចទទួលយកបាន ត្រូវបានបដិសេធ។

១៤. ផ្សេងពីនេះ បណ្តឹងឧទ្ធរណ៍ត្រូវបានបដិសេធ។

១៥. ជនជាប់ចោទត្រូវបានចោទប្រកាន់ និងត្រូវបានបង្គាប់ឱ្យបញ្ជូនខ្លួនជំនុំជម្រះដូចដែលបានចែងនៅក្នុងដីកាដំណោះស្រាយ ដែលត្រូវអានព្រមគ្នាជាមួយនឹងសាលដីកានេះ។

១៦. ការឃុំខ្លួនជនជាប់ចោទជាបណ្តោះអាសន្នត្រូវបានបង្គាប់ឱ្យបន្តចិរវេលា រហូតដល់ពេលដែលជនជាប់ចោទត្រូវបាននាំបង្ហាញខ្លួន នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង។

៣. ហេតុដូច្នេះ អង្គបុរេជំនុំជម្រះផ្តល់សំអាងហេតុ ចំពោះសេចក្តីសន្និដ្ឋានទាំងដប់ប្រាំមួយ នៃសាលដីកានេះ ដែលការឃុំខ្លួនបណ្តោះអាសន្នជនជាប់ចោទ ត្រូវបានបង្គាប់ឱ្យបន្តចិរវេលា។



ECCC PRE-TRIAL CHAMBER CHAMBRE PRÉLIMINAIRE

## រក្សាការឃុំខ្លួនបណ្ដោះអាសន្នជនជាប់ចោទ: សំអាងហេតុ

៤. អនុលោមតាមអនុវិធាន៦៨(២) នៅពេលបណ្ដឹងឧទ្ធរណ៍ត្រូវបានដាក់ប្រឆាំងនឹងដីកាបញ្ជូនរឿងទៅជំនុំជម្រះ មិនថាលក្ខណៈនៃបណ្ដឹងឧទ្ធរណ៍នោះយ៉ាងណាទេ "អានុភាពនៃដីកាឃុំខ្លួន ឬដីកាដោះលែងជនត្រូវចោទឱ្យនៅក្រៅឃុំរបស់សហចៅក្រមស៊ើបអង្កេត ត្រូវបន្តរហូតដល់មានសេចក្ដីសម្រេចពីអង្គបុរេជំនុំជម្រះ"។

៥. ជនជាប់ចោទមិនបានដាក់បណ្ដឹងឧទ្ធរណ៍ ប្រឆាំងនឹងដីកាឃុំខ្លួនរបស់សហចៅក្រមស៊ើបអង្កេត ដែលបានចេញនៅក្នុងដីកាដំណោះស្រាយ។ គ្មានកាលៈទេសៈពិសេសណា ក្រៅពីការអះអាងលើការបញ្ជូនរឿងទៅជំនុំជម្រះពីអង្គបុរេជំនុំជម្រះ ដែលធ្វើឱ្យរឹងមាំពីមូលហេតុដែលត្រូវបានរកឃើញ និងជឿជាក់យ៉ាងច្បាស់ថា ជននោះធ្លាប់បានប្រព្រឹត្តបទល្មើសមួយ ឬច្រើន ដូចមានចែងក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះ[៣]។ វាក៏ធ្វើឱ្យរឹងមាំផងដែរពីភាពចាំបាច់ ដើម្បីរក្សា នួន ជា ក្នុងការឃុំខ្លួនបណ្ដោះអាសន្ន ដើម្បីធានាអំពីវត្តមានរបស់គាត់នៅក្នុងដំណើរការនីតិវិធី ការពារសន្តិសុខគាត់ រក្សាសណ្ដាប់ធ្នាប់សាធារណៈ និងរារាំងកុំឱ្យជនជាប់ចោទនោះគាបសង្កត់ទៅលើសាក្សី ឬ ជនរងគ្រោះ ឬ បំផ្លាញភស្តុតាង ប្រសិនបើត្រូវបានដោះលែង[៤] និងដើម្បីរក្សា អៀង ធីរិទ្ធ ក្នុងការឃុំខ្លួនបណ្ដោះអាសន្ន ដើម្បីធានាអំពីវត្តមានរបស់គាត់នៅក្នុងដំណើរការនីតិវិធី ការពារសន្តិសុខគាត់ រក្សាសណ្ដាប់ធ្នាប់សាធារណៈ និងរារាំងកុំឱ្យជនជាប់ចោទនោះគាបសង្កត់ទៅលើសាក្សី ឬ ជនរងគ្រោះ ឬ បំផ្លាញភស្តុតាង ប្រសិនបើត្រូវបានដោះលែង[៥]។ អង្គបុរេជំនុំជម្រះពិចារណាឃើញថា មូលហេតុដែលផ្ដល់ឱ្យដោយសហចៅក្រមស៊ើបអង្កេត ដើម្បីបង្ហាញថា ជនជាប់ចោទរក្សាការឃុំខ្លួនបណ្ដោះអាសន្ន ដែលអង្គជំនុំជម្រះយកតាម មានយុត្តិកម្មថា អង្គជំនុំជម្រះបង្គាប់ថា ការឃុំខ្លួន

[៣] វិធានផ្ទៃក្នុង ៦៣(៣)(ក)។

[៤] វិធានផ្ទៃក្នុង ៦៣(៣)(ខ) ១ ដល់ ៥។

[៥] វិធានផ្ទៃក្នុង ៦៣(៣)(ខ) ១ ២ ៣ និង៥។

ជនជាប់ចោទជាបណ្ដោះអាសន្នត្រូវបានបង្គាប់ឲ្យបន្តចិរវេលា រហូតដល់ពេលដែលជនជាប់ចោទត្រូវបាននាំបង្ហាញខ្លួន នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង។

**ភ្នំពេញ ថ្ងៃទី២១ ខែមករា ឆ្នាំ២០១១**

**អង្គបុរេជំនុំជម្រះ** **ប្រធាន**

PRE-TRIAL CHAMBER * E.C.C.C. * C.E.T.C. * CHAMBRE PRELIMINAIRE

Rowan DOWNING ន័យ ធុល Catherine MARCHI-UHEL ហួត វុទ្ធី ប្រាក់ គឹមសាន